# ការសង្ខេបមេរៀន និងផែនទីបង្ហាញ

# សម័យកាលរបស់អ្នកធ្វើដំណើរលើមាគ៌ានៃជីវិត

## ផ្នែកទី១

## សេចក្តីផ្តើម

គោលបំណងនៃផែនទីនេះ គឺដើម្បីបង្ហាញនៅក្នុងវិធីធម្មតាមួយដែលព្រះជាម្ចាស់ទំនាក់ទំនងជាមួយមនុស្សទៅតាមសម័យកាល។ មាគ៌ានៃជីវិតចាប់ផ្តើមនៅសួនច្បារអេដែន ហើយរហូតដល់រាជាណាចក្រមួយពាន់ឆ្នាំនៅលើផែនដី។ សេចក្តីពីរដ៏ប្រសើរនៅក្នុងមាគ៌ាដែលប្រាប់ត្រួសៗ ទី១ មានដំណើរការទៅមុខក្នុងការបង្ហាញដោយព្រះជាម្ចាស់ចំពោះបុគ្គលម្នាក់ៗ ដែលបានជួបប្រទះនៅលើមាគ៌ានេះ។ ទី២ សុភាសិត ១៤:១២ "មនុស្សខ្លះយល់ថា ផ្លូវដែលខ្លួនដើរ ជាផ្លូវត្រឹមត្រូវក៏ប៉ុន្តែ នៅទីបំផុត ផ្លូវនោះនាំទៅរកសេចក្តីស្លាប់។"

មេរៀនទី១ **យើងរៀបចំសម្រាប់ការធ្វើដំណើររបស់យើងនៅលើមាគ៌ានៃជីវិត។** នៅក្នុងមេរៀននេះ យើងណែនាំសិស្ស ចំពោះគំនិតនៃការប្រើព្រះគម្ពីរដោយការប្រើផែនទី។ ការសិក្សាពាក្យនីមួយៗនៅក្នុងចំណងជើងជួយអោយសិស្សយល់ពីធម្មជាតិបន្តបន្ទាប់គ្នា។

មេរៀនទី២ **យើងចាប់ផ្តើមការធ្វើដំណើររបស់យើងជាមួយអ្នកធ្វើដំណើរដំបូងនៅលើមាគ៌ានៃជីវិត។** យើងចាប់ផ្តើមការធ្វើដំណើររបស់យើងនៅកន្លែងដែលចាប់ផ្តើមមានជីវិតនៅលើផែនដីនេះ នៅក្នុងសួនច្បារអេដែន ហើយដើរតាមមាគ៌ារបស់យើងទៅកាន់កន្លែងបញ្ចប់ជីវិតនៅលើផែនដីនេះ បន្ទាប់ពីរាជាណាចក្រមួយពាន់ឆ្នាំ។ ដូចជាយើងធ្វើដំណើរ យើងចាប់អារម្មណ៍ដែលមាគ៌ាបន្ត គឺតែងតែឆ្ពោះទៅមុខ។ យើងមើលពីរបៀបដែលព្រះជាម្ចាស់ស្រលាញ់ប្រជាជនរបស់ទ្រង់ ហើយដែលបន្តការបង្ហាញអង្គទ្រង់ផ្ទាល់ទៅកាន់ពួកគេ។ មានកន្លែងពីរដែលបង្ហាញកន្លែងដែលយើងរស់នៅសព្វថ្ងៃ គឺមាគ៌ានៃព្រះគុណ និងប្រលានយន្តហោះនៃព្រះគុណ។ ដំបូងអ្នកធ្វើដំណើរមិនបានស្តាប់បង្គាប់តាមផ្លូវដែលព្រះជាម្ចាស់បានផ្តល់ ហើយត្រូវដាច់ចេញពីព្រះជាម្ចាស់។ ព្រះជាម្ចាស់បានស្វែងរកពួកគេ ហើយជាមួយនឹងការសន្យាផ្តល់អ្នកប្រោសលោះម្នាក់ទៅពួកគេ ដោយតាមរយៈការបង្ហូរឈាមគឺជាការលើកលែងទោសនៃអំពើបាប (លោកុប្បត្តិ ១-៣)។

មេរៀនទី៣ **ក្មេងដំបូងនៅលើមាគ៌ានៃជីវិត**( លោកុប្បត្តិ៤:១-១៥)។ "ដោយសារជំនឿ លោកអេបិលបានថ្វាយយញ្ញបូជាមួទៅព្រះជាម្ចាស់ ជាយញ្ញបូជាប្រសើរជាងយញ្ញបូជារបស់លោកកាអ៊ីន។ ដោយសារជំនឿហ្នឹងហើយ បានជាព្រះជាម្ចាស់ផ្តល់សក្ខីភាព ថាលោកជាមនុស្សសុចរិត (ហេប្រឺ១១:៤)។ លោកកាអ៊ីនបានជ្រើសរើសផ្លូវមើលទៅដូចត្រឹមត្រូវ ប៉ុន្តែវាជាផ្លូវនាំទៅរកសេចក្តីស្លាប់។

មេរៀនទី៤ **អ្នកធ្វើដំណើរទៅអវកាសដំបូងគេនៅលើមាគ៌ានៃជីវិត** (លោកុប្បត្តិ៥:១-២៤)។ "លោកហេណុកបានដើរតាមមាគ៌ាព្រះជាម្ចាស់ ហើយគាត់បានបាត់ដោយព្រះជាម្ចាស់បានលើកគាត់ឡើង" "ដោយសារជំនឿលោកហេណុកត្រូវព្រះជាម្ចាស់លើកឡើងទៅស្ថានបរមសុខ រួចផុតពីសេចក្តីស្លាប់ ហើយគ្មាននរណារកលោកឃើញទៀតឡើយ...(ហេប្រឺ១១:៥)។ លោកហេណុកនិម្មិតសញ្ញាចំពោះអស់អ្នកដែលកំពុងរស់នៅក្នុងសម័យព្រះគុណនេះ(បានបង្ហាញដោយប្រលានយន្តហោះនៃព្រះគុណ) ដែលគេនឹងមិនឃើញសេចក្តីស្លាប់ឡើយ ប៉ុន្តែនឹងលើកឡើងទៅជួបនឹងព្រះជាម្ចាស់នៅលើអាកាសវេហាស៍(១ថេស្សាឡូនិក៤:១៣-១៧)។

មេរៀនទី៥ **គ្រលុកទឹកដ៏អស្ចារ្យនៅលើមាគ៌ានៃជីវិត**(លោកុប្បត្តិ៦)។ ជាមួយការកាន់តែកើនឡើងនៃចំនួនមនុស្ស បាបក៏កើនឡើងតាមនោះដែរ។ ព្រះជាម្ចាស់មានព្រះបន្ទូល "អញនឹងបំផ្លាញមនុសដែលអញបានបង្កើតចេញពីផែនដី។ ប៉ុន្តែលោកណូអេបានរកព្រះគុណនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ឃើញ។" ទូកធំបានសាងសងឡើង ទឹកបានមក ប៉ុន្តែលោកណូអេ និងក្រុមគ្រួសារបានទទួលសុវត្ថភាពនៅក្នុងទូកធំ។ ទ្វាររបស់ទូកធំចង់និយាយអំពីព្រះគ្រីស្ទ គឺទ្វានៃការសង្គ្រោះ។ បន្ទាប់ពីទឹកជំនន់ ព្រះជាម្ចាស់បានផ្តល់ច្បាប់នៃការធ្វើដំណើរថ្មីដល់អស់អ្នកដែលរស់នៅបន្ទាប់ពីទឹកជំនន់។

មេរៀនទី៦ **ការបែកជាពីរនៅក្នុងផ្លូវត្រង់កាច់ជ្រុងនៃការភាន់ច្រឡំ**(លោកុប្បត្តិ១១:១-១៥)។ បន្ទាប់ពីទឹកជំនន់ លោកណូអេ និងគ្រួសាររបស់គាត់បានចាប់ផ្តើមចេញទៅក្រៅជាមួយការចង់សម្ព័ន្ធមេត្រីថ្មី ព្រះជាម្ចាស់បានធ្វើជាមួយពួកគេ ដែលទ្រង់នឹងមិនដាក់ទឹកជំនន់ម្តងទៀតទេ ទោះបីមនុស្សកើនឡើង ហើយអំពើបាបកើនឡើងដ៏ដោយ។ ក្នុងការប៉ះបោប្រឆាំងនឹងព្រះជាម្ចាស់បានឈានកំរិតខ្ពស់បំផុតនៅប៉មបាបិល។ ជាលទ្ធផលគឺ "ព្រះជាម្ចាស់បោះបង់" ពួកគេ(The race) (រ៉ូម១:២៤, ២៦, ២៨) និងបានចាប់ផ្តើមនូវគម្រោងថ្មីមួយ។ ពូជសាសន៍ ឬជាសាសន៍ដូចជាអ្វីដែល

គេបានហៅ, បានបិទនៅលើ "មាគ៌ានៃសាសន៍ដទៃ" ខណៈពេលព្រះជាម្ចាស់បានត្រាស់ហៅលោក អាប់រ៉ាម ទៅជាផ្នែកនៃផែនការទ្រង់ ដែលតាមរយៈគាត់ពិភពលោកនឹងបានទទួលព្រះពរ។

មេរៀនទី៧ **ការធ្វើដំណើរនៅលើផ្លូវនៃការសន្យា**(លោកុប្បត្តិ១២-៣៦)។ ចំពោះលោកអប្រាហាម ព្រះជាម្ចាស់បានផ្តល់ការសន្យាថាប្រទានជាតិសាសន៍មួយអោយ និងពូជពង្សរបស់គាត់ជាទីបញ្ចេញព្រះពរទៅពិភពលោក។ អប្រាហាមបានជឿលើព្រះជាម្ចាស់ និងត្រូវបានរាប់គាត់ថាជាមនុស្សសុចរិត(រ៉ូម៤:៣)។ ការសន្យាត្រូវបានផ្តល់បន្តទៅលោកអ៊ីសាក និងលោកយ៉ាកុប។

មេរៀនទី៨ **ផ្លូវសន្យាបតបែននៅចន្លោះស្រុកអេស៊ីប**(លោកុប្បត្តិ៣៧-៥០)។ ព្រះជាម្ចាស់បានប្រាប់អប្រាហាមថាកូនចៅរបស់គាត់នឹងទទួលបានបទពិសោធន៍នៅក្នុងទឹកដីដ៏ចំឡែក ដែលពួកគេនឹងត្រូវទទួលការរងទុក្ខវេទនា និងត្រូវបម្រើ ៤០០ឆ្នាំ មុននឹងបញ្ជូនអោយទៅ។ (លោកុប្បត្តិ១៥:១៣,១៤) ទំនាយនេះត្រូវបានបំពេញនៅក្នុងជីវិតរបស់លោកយ៉ូសែប។ នៅកៀកនៃកំណើតពិភពលោក លោកយ៉ាកុប និងក្រុមគ្រួសាររបស់គាត់ទាំងអស់ត្រូវបាននាំទៅទឹកដីអេស៊ីបដោយលោកយ៉ូសែប ហើយបានផ្តល់កន្លែងរស់នៅក្នុងទឹកដីកូសែន។

មេរៀនទី៩ **ការរំលងមួយ និងការឆ្លងកាត់មួយនៅលើផ្លូវសន្យា**(និក្ខមនំ១-១៤)។ បន្ទាប់ពីការស្លាប់របស់លោកយ៉ូសែបប្រជាជនអ៊ីស្រាអែលបានទទួលរងទុក្ខវេទនាយ៉ាងឃោរឃៅនៅស្រុកអេស៊ីប។ ព្រះជាម្ចាស់បានបញ្ជូនគ្រោះកាចយ៉ាងដាក់ស្រុកអេស៊ីប ហើយគ្រោះកាចចុងក្រោយគឺសំលាប់កូនច្បង។ ទេវតានៃសេចក្តីស្លាប់មកសំលាប់ ប៉ុន្តែចំពោះផ្ទះណាដែលបានលាបឈាមសត្វនៃយញ្ញបូជានៅលើគ្រប់ទ្វាផ្ទះទេវតានឹងហោះ**រំលង**។ បន្ទាប់មកលោកម៉ូសេបានដឹកនាំប្រជាជនចេញទៅ។ ខណៈដែលពួកគេបានមកដល់សមុទ្រក្រហម ព្រះជាម្ចាស់បានញែកទឹកសមុទ្រ និងអោយពួកគេដើរ**ឆ្លងកាត់**នៅដីស្ងួត។

មេរៀនទី១០ **ស្រមោលភ្នំមួយនៅលើផ្លូវសន្យា**(និក្ខមនំ១៥-៣២)។ បន្ទាប់មកលោកម៉ូសេបានដឹកនាំប្រជាជនអ៊ីស្រាអែលចូលទៅវាលរហោឋានស៊ីណៃជាកន្លែងដែលពួកគេត្រូវល្បងល និងបង្ហាញពីភាពត្រៀមខ្លួនជាស្រេចរបស់ពួកគេ ដើម្បីចូលទៅក្នុងទឹកដីសន្យា។ ពីព្រោះពួកគេបានបង្ហាញប៉ះបោមួយដែលពេញដោយអំពើបាប ព្រះជាម្ចាស់ប្រទាននូវក្រឹត្យវិន័យអោយពួកគេ សម្រាប់នេះ "ដោយសារក្រឹត្យវិន័យនោះយើងមានចំណេះដឹងនៃអំពើបាប"។ ក្រឹត្យវិន័យបានបំពេញបន្ថែមចំពោះការសន្យា ដែលបានផ្តល់ទៅលោកអប្រាហាម។ លោកអ៊ីសាក និងលោកយ៉ាកុបនៃជាតិសាសន៍មួយ និងអ្នករំដោះដែលនៅថ្ងៃណាមួយព្រះពរនឹងដល់ពិភពលោក។ ក្រឹត្យវិន័យមិនបានផ្តល់អោយទៅអស់អ្នកណាដែលរស់នៅផ្នែកនៃឈើឆ្កាងនេះ និងអស់អ្នកណាដែលជាសមាជិកនៃរូបកាយនៃព្រះគ្រីស្ទឡើយ ប៉ុន្តែក្រឹត្យវិន័យជាក្រុម

ដែលដាក់លើប្រជាជនដែលស្គាល់គោលការណ៍សីលធម៌របស់ព្រះជាម្ចាស់ ហើយដែលជាអំពើបាបនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់(កាឡាទី៣:៩; រ៉ូម៣:២០)។

មេរៀនទី១១ **ក្រោមក្រឹត្យវិន័យនៅលើផ្លូវសន្យា**(ជនគណនា៨-១៤). ព្រមជាមួយគ្នានឹងក្រឹត្យវិន័យ ១០ប្រការ ព្រះជាម្ចាស់បានផ្តល់អោយច្បាប់ និងលិខិតបទដ្ឋានផ្សេងៗនៃរបៀបប្រជាជនត្រូវថ្វាយបង្គំ រស់នៅ និងឥរិយាបថទៅកាន់អ្នកដទៃ ហើយនិងរបៀបដែលពួកគេត្រូវធ្វើដំណើរ។ ខណៈពេលពួកគេបន្តដំណើរនៅលើផ្លូវសន្យា ពួកគេបានរអ៊ូរទាំលើរាល់ឧបសគ្គ និងបានគំរាមគំហែងដល់ជីវិតលោកម៉ូសេទៀតផង។ម្តងហើយម្តងទៀត លោកម៉ូសេបានធ្វើជាអ្នកសម្របសម្រួលរវាងប្រជាជន និងព្រះពិរោធរបស់ព្រះជាម្ចាស់។ ការប៉ះបោដ៏ខ្លាំងបំផុតគឺការបដិសេធចំពោះការចូលទៅក្នុងទឹកដីសន្យា ហើយជាលទ្ធផលនៃជាតិសាសន៍នេះគឺការថ្កោលទោស ចំពោះការដើរត្រាចចរនៅក្នុងវាលរហោឋាន៤០ឆ្នាំ រហូតដល់ជំនាន់អ្នកដែលប៉ះបោស្លាប់អស់។

មេរៀនទី១២ **លោកយ៉ូស្វេដឹកនាំចូលទឹកដីសន្យា**(យ៉ូស្វេ១-១១). ពីព្រោះតែលោកយ៉ូស្វេ និងកាលែបអនុវត្តសេចក្តីជំនឿ និងការស្តាប់បង្គាប់ ពួកគេអាចអនុញ្ញាតអោយចូលទៅក្នុងទឹកដីសន្យា។ លោកយ៉ូស្វេត្រូវបានជ្រើសរើសជាអ្នកដឹកនាំ។ ពួកគេបានឆ្លងកាត់ទន្លេយ័រដាន់នៅលើគ្រង់កន្លែងដីស្ងួត(យ៉ូស្វេ៣)។ ពួកគេបានមើលទៅក្រុងយេរីខូដ៏អស្ចារ្យ ហើយពួកគេបានអនុវត្តដោយការស្តាប់បង្គាប់ នឹងភ្លាមៗពួកគេបានវាយដណ្តើមយកទឹកដី។ ពេលបានហើយ ពួកគេបានចូលទៅ ត្រួតត្រាលើទឹកដីនោះ ហើយបានបែងចែករទឹកដីទាំងនោះជា១២កុលសម្ព័ន្ធ។

មេរៀនទី១៣ **សរុបពីមេរៀនទី១ ដល់ ទី១២**

## ផ្នែកទី២

មេរៀនទី១៤ **ពីផ្លូវនៃការសន្យាទៅកាន់ផ្លូវធំនៃរាជាណាចក្រ** (១សាំយ៉ូអែល៨ - ២សាំយ៉ូអែល៦). បន្ទាប់ពីការស្លាប់របស់លោកយ៉ូស្វេ "នៅគ្រានោះ ស្រុកអ៊ីស្រាអែលគ្មានស្តេចសោយរាជ្យទេ ម្នាក់ៗធ្វើអ្វីៗតាមតែខ្លួនយល់ឃើញ" (ចៅហ្វាយ២១:២៥)។ លទ្ធផលនេះ នៅក្នុងភាពវិកវរច្របូកច្របល់ អ៊ីស្រាអែលបានស្រែកយំទៅកាន់ព្រះជាម្ចាស់ សុំស្តេចមួយអង្គ ដើម្បីគ្រប់គ្រងលើពួកគេ។ ជាមួយការចាប់ផ្តើមមានស្តេច **ផ្លូវនៃការសន្យា**បានក្លាយជា**ផ្លូវធំនៃរាជាណាចក្រ**វិញ។ ព្រះជាម្ចាស់បានសង្កត់ធ្ងន់ម្តងទៀតលើច្បាប់ធ្វើដំណើរ ដែលត្រូវតែធ្វើតាមដើម្បីទទួលព្រះពរពីទ្រង់ ប៉ុន្តែស្តេចសូល ដែលជាស្តេចដំបូងបានធ្លាក់ចុះព្រោះតែការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ បន្ទាប់មកលើកដាវីឌជាស្តេចដោយព្រោះស្តាប់បង្គាប់ និងជាទី

គាប់ព្រះហឫទ័យព្រះជាម្ចាស់ គាត់បានទទួលជោគជ័យ និងត្រូវជ្រើសរើសម្នាក់តាមរយៈគាត់ ដែលការសន្យាដាក់អ្នកសង្គ្រោះ គឺស្តេចនោះនឹងមក។

មេរៀនទី១៥ **ភាពរុងរឿងនៃរាជាណាចក្ររបស់ស្តេចសាលឡូម៉ូន**(១ពង្សាវតារក្សត្រ១-១២; ១របាក្សត្រ១-៩)។ មុននឹងគាត់ស្លាប់ ស្តេចដាវិឌមានសាលឡូម៉ូនឡើងគ្រងរាជ្យបន្ត។ ពេលស្តេចសាលឡូម៉ូនបានទៅគីបៀន ដើម្បីថ្វាយដង្វាយដុត ព្រះជាម្ចាស់បានលិចមកអោយគាត់ឃើញក្នុងសុបិន្តដោយសន្យាថានឹងផ្តល់អោយនូវអ្វីដែលគាត់ទូលសុំពីទ្រង់។ ដោយសារស្តេចសាលឡូម៉ូនបានទូលសុំប្រាជ្ញា ដើម្បីគ្រប់គ្រងប្រជារាស្ត្រព្រះអង្គបានល្អប្រសើរ ព្រះជាម្ចាស់មានព្រះបន្ទូលថា ទ្រង់នឹងប្រទានពរអោយគាត់ជាអ្នកមាន និងមានគោរព។ ជាលទ្ធិផល រាជាណាចក្រអ៊ីស្រាអែលបានក្លាយជារុងរឿងក្រោមស្តេចសាលឡូម៉ូន។ វាគឺសំខាន់ ពីព្រោះ វាផ្តល់អោយការង្ហាញមុននៃអ្វី ដែលជាសន្យាពីរាជាណាចក្រឋានសួគ៌នឹងកើតឡើងកំឡុងពេលការគ្រងរាជ្យ១០០០ឆ្នាំរបស់ព្រះគ្រីស្ទ ដូចជាបានចង្អុលបង្ហាញនៅលើ**ផែនទី** ដោយ**រាជាណាចក្រភ្នំបរិសុទ្ធ**។

មេរៀនទី១៦ **ការបង្ខាំងត្រង់ចំណុចបត់បែន**(ពង្សាវតារក្សត្រ និង របាក្សត្រ)។ ពេលដែលព្រះជាម្ចាស់ប្រទានក្រឹត្យវិន័យអោយអ៊ីស្រាអែល ទ្រង់បានប្រាប់ពួកគេថា បើស្តាប់បង្គាប់នឹងទទួលបានព្រះពរ ប៉ុន្តែបើមិនស្តាប់បង្គាប់នឹងទទួលបណ្តាសារ(លេវីវិន័យ ២៦)។ ពេលស្តេចសាលឡូម៉ូនកាន់តែចាស់ទៅៗប្រពន្ធរបស់គាត់ដែលមិនជឿព្រះជាម្ចាស់បានដឹកនាំគាត់ទៅគោរពព្រះក្លែងក្លាយ(រូបសំណាកផ្សេងៗ)។ ព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ ហើយមានព្រះបន្ទូលទៅគាត់ថា "ដោយអ្នកប្រព្រឹត្តដូច្នេះ គឺអ្នកមិនបានគោរពសម្ព័ន្ធមេត្រីរបស់យើង... យើងនឹងដករាជសម្បត្តិចេញពីអ្នក... ប៉ុន្តែកំឡុងពេលកូនរបស់អ្នក" (១ពង្សាវតារក្សត្រ១១:១១-១៣)។ ដូចជាបានទាយ នៅក្រោមការគ្រប់គ្រងរបស់ស្តេចរ៉េហូបោមបានបែងចែកទឹកដីជាមួយការប៉ះបោររបស់ស្តេចយេរ៉ូបោម។ បន្ទាប់មកស្តេចដែលគ្រងរាជ្យក្រោយៗជាធម្មតាគឺជាស្តេចអាក្រក់ និងគោរពព្រះក្លែងក្លាយ ការវិនិច្ឆ័យទោស ដំបូងលើរាជាណាចក្រអ៊ីស្រាអែល ឆ្នាំ៧២២ មុនគ្រីស្ទសករាជ ក្រោយមកលើរាជាណាចក្រយូដា ឆ្នាំ៥៨៦មុនគ្រីស្ទសករាជ។ នេះគឺបានបង្ហាញនៅលើផែនទីត្រង់ចំណុច**ការបង្ខាំងត្រង់ចំណុចបត់បែន**។ វាគឺជាផ្លូវមួយបត់បែនចុះឡើង និងវិញចូលគ្នាដោយសារអំពើបាប។

មេរៀនទី១៧ **ព្យាការីមើលឃើញកំពូលភ្នំពីរ** (១ពង្សាវតារក្សត្រ-ម៉ាឡាគី). នៅពេលដែលរបបនយោបាយដឹកនាំរបស់អ៊ីស្រាអែលបានចាប់ផ្តើមធ្លាក់ចុះ ព្រះជាម្ចាស់បានចាប់ផ្តើមលើកអ្នកដឹកនាំសាសនាគឺពួកព្យាការី។ ពួកគេបានប្រកាសព្រះបន្ទូលមួយជាពីរ គឺអ្នកសង្គ្រោះ - ស្តេចនឹងយាងមក។ ពួកគេបាននិយាយការឈឺចាប់របស់ស្តេចនៅលើភ្នំកាល់វ៉ារី ហើយនិងសិរីរុងរឿងរបស់ស្តេច និងរាជាណាចក្រដែល

គួរដើរតាម(លើភ្នំស៊ីយ៉ូន ឬ ភ្នំនៃរាជាណាចក្រ)។ (១ពេត្រុស ១:១១) អ្វីដែលព្យាការីមើលមិនឃើញគឺនៅចន្លោះនៃជ្រលងភ្នំទាំងពីរ(មាគ៌ានៃព្រះគុណ និងប្រលានយន្តហោះនៃព្រះគុណ) ការបង្ហាញភាពលាក់កំបាំងក្នុងសម័យកាលព្រះគុណ។

មេរៀនទី១៨ **សង្កេតមើល! ព្រះមហាក្សត្រយាងមក** (ដំណឹងល្អ). សម្រាប់៤០០ឆ្នាំ ព្រះជាម្ចាស់បានរក្សាភាពស្ងាត់ស្ងៀម ហើយបន្ទាប់មកក៏បានលឺសំលេងលោកយ៉ូហានបាទីស្ត "ចូរកែប្រែចិត្តគំនិតឡើង ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ! ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតំរង់ផ្លូវថ្វាយព្រះអង្គ។" ផ្លូវធំនៃរាជាណាចក្រត្រូវតែរៀបចំ និងតំរង់សម្រាប់ការយាងមករបស់ព្រះមហាក្សត្រ។ (ម៉ាថាយ៣:២៣) ព្រះយេស៊ូបានបង្ហាញ ដោយប្រកាស់ថាទ្រង់ជាព្រះបុត្រានៃព្រះជាម្ចាស់ ជាស្តេចនៃសាសន៍អ៊ីស្រាអែល និងព្រះសង្គ្រោះពិភពលោក ប៉ុន្តែជាតិសាសន៍អ៊ីស្រាអែលមិនបានទទួលស្វាគមន៍ស្តេចរបស់ពួកគេឡើយ។

មេរៀនទី១៩ **ភ្នំកាល់វ៉ារីស្រមោលនៃផ្លូវធំនៃរាជាណាចក្រ** (ដំណឹងល្អ) ។ ខណៈដែលយើងធ្វើដំណើរ យើងមកកាន់តែកៀកកំពូលភ្នំទី១ ដែលបានមើលឃើញដោយព្យាការី គឺភ្នំកាលវ៉ារី។ បន្ទាប់មកព្រះគ្រីស្ទយាងចូលទៅក្នុងក្រុងយេរ៉ូសាឡិមដោយជិះសត្វលា ទ្រង់បានយាងទៅព្រះវិហារ ហើយទ្រង់បានចាប់របស់របរអ្នកលក់ចោលដែលលក់នៅព្រះវិហារចោល បានចាប់ផ្តើមព្យាបាលមនុស្សខ្វាក់ និងមនុស្សខ្វិនដៃជើង។ មេដឹកនាំសាសនាបានឃើញ អ្វីដែលទ្រង់បានធ្វើ និងបានលឺក្មេងៗស្រែកច្រៀង "ហូសាណា ព្រះបុត្រារបស់ស្តេចដាវីឌ"។ ពួកគេមិនពេញចិត្ត ហើយបានចាប់ផ្តើមរៀបផែនការសម្ងាត់ដែលអាចចាប់ព្រះយេស៊ូបាន និងសម្លាប់ទ្រង់។ ព្រឹត្តិការណ៍ដើរដំណាក់កាលលំដាប់យ៉ាងរហ័ស ដែលឈានដល់លទ្ធផលជាក់លាក់ជាមួយការឆ្កាង។ ដូចបានទាយ នៅថ្ងៃទី៣ ទ្រង់នឹងរស់ឡើងវិញ និងមានមនុស្សជាច្រើននាក់បានទ្រង់យាងឡើងទៅឋានសួគ៌។

មេរៀនទី២០ **លោកពេត្រុសដឹកនាំធ្វើដំណើរនៅលើផ្លូវធំនៃរាជាណាចក្រ** (កិច្ចការ១-៧). នៅថ្ងៃបុណ្យទី៥០ បន្ទាប់ពីព្រះយេស៊ូយាងទៅ គឺពួកសាវ័កបាននាំគ្នារង់ចាំ និងអធិដ្ឋាន ពួកគេបានលឺសំលេងមួយមកពីលើមេឃដូចជាខ្យល់បក់បោកយ៉ាងខ្លាំង ហើយម្នាក់ៗដែលកំពុងរងចាំបានបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ នេះគឺជាបុណ្យថ្ងៃទី៥០។ លោកពេត្រុសបានឈរឡើង និងចែកចាយព្រះបន្ទូលពេញដោយអំណាចេស្តា។ គាត់បានពន្យល់ថាព្រះអម្ចាស់បានប្រោសព្រះយេស៊ូអោយមានព្រះជន្មរស់ឡើងវិញ ទ្រង់បានត្រលប់មកវិញ និងរៀបចំ**រាជាណាចក្រ**ទៅអ៊ីស្រាអែលឡើងវិញ ប្រសិនបើគេកែប្រែចិត្តគំនិតទទួលពិធីជ្រមុជទឹក និងទទួលយកព្រះជាម្ចាស់។ មនុស្សជាង៣០០០នាក់បានជឿ ប៉ុន្តែពួកមេដឹកនាំនូវតែបន្តការបដិសេធ។ នៅក្នុងផ្លូវនេះលោកពេត្រុសបានក្លាយជាអ្នកដឹកនាំនៃការធ្វើដំណើរ ប៉ុន្តែគាត់ធ្វើការ

ចែកចាយទៅកាន់តែជាតិសាសន៍មួយប៉ុណ្ណោះ គឺសាសន៍យូដា។ ជាមួយការបដិសេធដោយអ្នកដឹកនាំអ្នកមិនជឿបានប្រឆាំងបិទគម្រោងការនៃរាជាណាចក្រ។

មេរៀនទី២១ **មាគ៌ានៃសាសន៍ដទៃចូលរួមជាមួយផ្លូវធំនៃរាជាណាចក្រ** (កិច្ចការ៧-១២). ខណៈដែលអ៊ីស្រាអែលនូវបន្តបដិសេធស្តេចដែលរស់ឡើងវិញ និងរាជាណាចក្ររបស់ទ្រង់ ព្រះអម្ចាស់បានចាប់ផ្តើមរៀបចំនូវមាគ៌ាដែលជាគោលបំណងថ្មីមួយ ដែលទ្រង់មិនដែលបានបង្ហាញឡើយ។ ទ្រង់បានសង្គ្រោះសូល(ក្រោយមកហៅថាប៉ូល) ជាសាវ័កទៅកាន់សាសន៍ដទៃ។

មេរៀនទី២២ **លោកពេត្រុសឆ្លងកាត់មាគ៌ានៃសាសន៍ដទៃ** (កិច្ចការ១០-១២). លោកពេត្រុសបានកំពុងរីករាយជាមួយការងារជាអ្នកដឹកនាំក្នុងការធ្វើដំណើរនៅលើ**ផ្លូវធំនៃរាជាណាចក្រ** និងការបង្ហាញពីអំណាចដោយការធ្វើទីសំគាល់អស្ចារ្យ។ បន្ទាប់មកនៅថ្ងៃមួយពេលលោកពេត្រុសបានឡើងទៅលើដំបូងផ្ទះដើម្បីអធិដ្ឋាន គាត់បានទទួលនូវការមួយតាមរយៈ ដែលគាត់បានក្តាប់ជាប់គំនិត ដែលព្រះជាម្ចាស់ចង់អោយគាត់ទៅសាសន៍ដទៃ គឺផ្ទះលោកកូនេលាស និងប្រាប់គាត់ពីដំណឹងល្អនៃការសុគតរបស់ព្រះគ្រីស្ទ និងការរស់ឡើងវិញ។ ពេលដែលលោកពេត្រុសបានស្តាប់តាមការបង្ហាញនេះ គឺលោកកូនេលាស និងក្រុមគ្រួសារគាត់ទាំងមូលបានទទួលការសង្គ្រោះ។ ទោះជាយ៉ាងណា លោកពេត្រុសបានចែកចាយពីបុណ្យថ្ងៃទី៥០ដំណឹងល្អនៃរាជាណាចក្រទៅលោកកូនេលាស គាត់បានចាប់ផ្តើមយល់ថាព្រះអម្ចាស់បានកំពុងរៀបចំបើកនូវគម្រោងផែនការថ្មីឡើង ដែលនឹងទៅកាន់មនុស្សទាំងអស់ គឺយូដា និង សាសន៍ដទៃដូចគ្នា។

មេរៀនទី២៣ **ផ្លូវធំឌុប(Double Highway) ពីមាគ៌ានៃសាសន៍ដទៃទៅកាន់មាគ៌ានៃព្រះគុណ** (កិច្ចការ១៣-២៨). ព្រះវិញ្ញាណបរិសុទ្ធបានត្រាសហៅលោកប៉ូល ដើម្បីញែកគាត់សម្រាប់បំពេញការងារ ពិសេសព្រះអម្ចាស់បានធ្វើជាបេសកជនទៅកាន់សាសន៍ដទៃ។ ខណៈដែលគាត់បានបន្តដំណើរបំពេញបេសកកម្មរបស់គាត់នៅរាល់ទីក្រុង គាត់បានទៅដំបូងគឺទៅកាន់វិហារពួកយូដា និងបានចែកចាយ ព្រះយេស៊ូទៅកាន់ជនជាតិអ៊ីស្រាអែល។ នៅពេលដែលពួកគេបានបដិសេធព្រះបន្ទូល បន្ទាប់មកគាត់ បានបែរពួកគេទៅកាន់សាសន៍ដទៃវិញ។ (កិច្ចការ១៣:៤៦; ១៨:៦; ២៨:២៨) ដូច្នេះហើយបានជាលោក ប៉ូលឆ្លងកាត់ទៅមុខទៅក្រោយ ខណៈដែលគាត់ធ្វើដំណើរនៅលើ**ផ្លូវវត្ថុសធំ**ដ៏អស្ចារ្យហ្នឹង។ ជាមួយការបដិ សេធចុងក្រោយរបស់អ៊ីស្រាអែលនៅក្រុងរ៉ូម វាហាក់បីដូចជាបិទមិនអោយឆ្លងកាត់ផ្លូវធំនៃរាជាណាចក្រហើយនិងអ្វីដែលធ្លាប់តែបានមុនរបស់អ៊ីស្រាអែលត្រូវបានបញ្ចប់។

មេរៀនទី២៤ **លោកប៉ូលអ្នកបើកយន្តហោះនៃការសង្គ្រោះ** (លិខិតឧទ្ទិសរបស់លោកប៉ូល)។ ជាមួយការធ្លាក់ចុះរបស់អ៊ីស្រាអែលបានមកបំពេញការបង្ហាញនៃសម័យកាលព្រះគុណរបស់ព្រះជាម្ចាស់។

នៅក្នុងមេរៀននេះមានបុគ្គលិកលក្ខណៈបួនយ៉ាងដែលបានសង្កត់ធ្ងន់ក្នុងសម័យកាលព្រះគុណគឺៈ យូដា និងសាសន៍ដទៃជា**ព្រះកាយតែមួយ**នៅក្នុងព្រះគ្រីស្ទ; ព្រះគ្រីស្ទជាសិរសា និងអ្នកជឿជាសមាជិកនៃ**ព្រះកាយតែមួយ**; ព្រះវិញ្ញាណបរិសុទ្ធតែមួយជ្រមុជ ធ្វើអោយសមាជិកទាំងអស់ចូលទៅក្នុង**ព្រះកាយតែមួយ;** ក្តីសង្ឃឹមតែមួយ អនាគតការលើកឡើងក្រុមជំនុំ ឬព្រះកាយទៅជាមួយព្រះគ្រីស្ទ ដែលជាសិរសានៃ**ព្រះកាយតែមួយ**។ យន្តហោះនៃការសង្រ្គោះបង្ហាញថារូបកាយជាក់ស្តែងនៅលើផែនដី ដែលនៅថ្ងៃណាមួយនឹងត្រូវទៅជួបនឹងព្រះជាម្ចាស់នៅលើអាកាសវេហាស៍។ លិខិតនេះគឺទៅកាន់ទាំងអស់គ្រប់ទីកន្លែង។

មេរៀនទី២៥ **ឆ្លងកាត់ជ្រលងនៃទុក្ខលំបាកទៅកាន់រាជាណាចក្រ** (វិវរណៈ). បន្ទាប់ពី**ព្រះកាយ**បានបំពេញហើយ ព្រះអម្ចាស់នឹងមានទំនាក់ទំនងជាមួយអ៊ីស្រាអែលម្តងទៀត។ **ផ្លូវធំនៃរាជាណាចក្រ**នឹងចាប់ផ្តើមបើកម្តងទៀត ប៉ុន្តែអ្នកដែលចូលទៅកាន់**រាជាណាចក្រ**ត្រូវតែឆ្លងកាត់**ជ្រលងនៃទុក្ខលំបាក**។ កំឡុងពេលនៃការឈឺចាប់នេះអ៊ីស្រាអែលនឹងយំអង្វរកព្រះជាម្ចាស់ ហើយបន្ទាប់មក "អ៊ីស្រាអែលទាំងអស់នឹងទទួលការសង្រ្គោះ... ព្រះអង្គដែលរំដោះ នឹងយាងចេញពីក្រុងស៊ីយ៉ូន ព្រះអង្គនឹងដកអំពើទមិឡចេញពីកូនចៅលោកយ៉ាកុប (រ៉ូម១១:២៦)។ **រាជាណាចក្រ**ដ៏រុងរឿងដែលបានសន្យានឹងចាប់ផ្តើមឡើង ហើយព្រះគ្រីស្ទនឹងគ្រងរាជ្យជា**ស្តេចអស់លើទាំងស្តេច** និងជា**ព្រះអស់លើទាំងព្រះ** សម្រាប់រយៈពេល ១០០០ឆ្នាំ។

**សេចក្តសន្និដ្ឋានៈ** ការបំពេញគម្រោងផែនការរបស់ព្រះជាម្ចាស់នេះគឺសម្រាប់នៅលើផែនដី និងការធ្វើដំណើររបស់យើងនៅក្នុង**មាគ៌ានៃជីវិត**។ ការធ្វើដំណើរតែងតែឆ្ពោះទៅមុខនៅលើផ្លូវតែមួយគត។ វាគឺជាផ្លូវមួយ( It is a ONE-WAY road)។ គ្មានឪកាសជាលើកទី២នោះទេបន្ទាប់ពីសេចក្តីស្លាប់ទៅ។ អស់អ្នកណាដែលចូលទៅកាន់ផ្ទៃមេឃថ្មី និងផែនដីថ្មី គឺអស់អ្នកណាដែលជ្រើសរើសផ្លូវនៃជីវិតនៅលើផែនដីនេះ។ សព្វនេះជាថ្ងៃនៃព្រះគុណរបស់ព្រះអម្ចាស់ ថ្ងៃនៃការសង្រ្គោះ។ ថ្វីបើភាពផ្សេងៗនៅក្នុងច្បាប់ធ្វើដំណើរក៏ដោយ គឺ "ផ្លូវនៃជំនឿ" គឺតែងតែជា "ផ្លូវត្រឹមត្រូវ"។ ព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំហ្នឹងហើយជាផ្លូវ... គ្មាននរណាម្នាក់ទៅកាន់ព្រះបិតាបានឡើយ លើកលែងតែតាមរយៈខ្ញុំ" (យ៉ូហាន ១៤:៦)។